ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី៥ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧

រៀបចំដោយ៖ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយ៖ ថវិកាជាតិ

## ១. សេចក្តីផ្តើម៖

នៅព្រឹកថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៥ សម្រាប់ឆ្នាំ២០១៧ ក្រោមការដឹកនាំរបស់ **ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង-ស្ថាប័ន ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើការងារមេរោគអេដស៍ និងជំងឺអេដស៍។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីថវិកាជាតិ។

## ២. គោលបំណងនៃកិច្ចប្រជុំ៖

ដើម្បីបង្ហាញពីរបាយការណ៍វឌ្ឍនភាព សមិទ្ធផល និងទិសដៅបន្តក្នុងការឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ ព្រមទាំងពិភាក្សា សម្របសម្រួលការងារបច្ចេកទេសតាមរបៀបវារៈ ដូចខាងក្រោម៖

-មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំ

-របាយការណ៍ប្រចាំខែ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-ការពន្យល់ណែនាំលើលិខិតមួយចំនួន ដែលអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានជម្រាបជូនទៅក្រសួង-ស្ថាប័ន។

-និងបញ្ហាផ្សេងៗ។

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណ ដល់សមាជិក-សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ដែលបានអញ្ជើញចូលរួមនាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុក។

**ប្រធានបទទី១: ឯកឧត្តមវេជ្ជបណ្ឌិត ជា ប៉ោ** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជម្រាបជូនពីរបាយការណ៍សង្ខេបរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានអនុវត្តនៅក្នុងខែមិថុនា ឆ្នាំ២០១៧ ដូចខាងក្រោម៖

- ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ នៅខេត្តបាត់ដំបង ឯកឧត្តមអគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមការងារបច្ចេកទេសថ្នាក់ជាតិ បុរសស្រលាញ់បុរស និងស្រីស្រស់ បានចូលរួមដឹកនាំកិច្ចប្រជុំសម្របសម្រួលថ្នាក់ខេត្ត ក្រោមប្រធានបទ " លើកកម្ពស់បរិយាកាសគាំទ្រសម្រាប់កម្មវិធីបង្ការមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមប្រឈមមុខខ្ពស់" ។
- បានប្រជុំពិនិត្យ កែសម្រួលទម្រង់របាយការណ៍សកម្មភាព និងសមិទ្ធផលការងារប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំឆមាសទី១ ឆ្នាំ២០១៧ សម្រាប់កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ ឯកសារដែលបានទទួលមាន១៦ ក្រសួង រាជធានី/ខេត្ត១៥ កាកបាទក្រហមកម្ពុជានិងអង្គការចំនួន៣។

- នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ នៅខេត្តសៀមរាប ឯកឧត្តមអគ្គលេខាធិការ បានអញ្ជើញចូលរួមដឹកនាំ និងសម្របសម្រួល ក្នុងកម្មវិធីផ្សព្វផ្សាយចំណុចគន្លឹះៗនៃប្រកាសលេខ០៨៦ និងកិច្ចពិភាក្សាក្នុងវេទិកាសម្របសម្រួលដើម្បីពង្រឹងកិច្ចសហការជាមួយផ្នែកពាក់ព័ន្ធក្នុងការអនុវត្តកម្មវិធីស្មាតហ្គីល ។

- ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ នៅខេត្តកណ្តាល ឯកឧត្តមអគ្គលេខាធិការ បានអញ្ជើញចូលរួមធ្វើជាវាគ្មិន ក្នុងកម្មវិធីផ្សព្វផ្សាយស្តីពីបច្ចុប្បន្នភាពនៃការរីករាលដាលមេរោគអេដស៍ និងការប្រឈមមុខរបស់យុវវ័យនៅកម្ពុជា ជូនដល់សិក្ខាកាមចំនួន៥០០នាក់ ដែលជានាយទាហានបញ្ជាការដ្ឋានកងពលតូចទ័ពពិសេសធ័ត្រយោង៩១១ អគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ។ ឯកឧត្តមអគ្គលេខាធិការ បានថ្លែងអំណរគុណដល់ឯកឧត្តមឧត្តមសេនីយឯក មេបញ្ជាការ មេបញ្ជាការរង យោធាចារ្យ និងពលទាហានទាំងអស់ដែលបានចូលរួម និងយកចិត្តដាក់ស្តាប់រួមទាំងមានការប្តេជ្ញាចិត្តខ្ពស់ ហើយក៏សូមអរគុណឯកឧត្តម ឧត្តមសេនីយទោ នាយករង និងសហការីនៃទីចាត់ការសុខាភិបាលនៃអគ្គបញ្ជាការដ្ឋាន ដែលបានជួយសម្របសម្រួលប្រកបដោយស្មារតីទទួលខុសត្រូវ។

- ថ្ងៃទី១៩-២៣ ខែមិថុនា ឆ្នាំ២០១៧ នាយកដ្ឋានសុខាភិបាលក្រសួងការពារជាតិ បានសហការជាមួយអង្គការមូលនិធិថែទាំសុខភាពអ្នកជំងឺអេដស៍(AHF)បានចុះធ្វើតេស្តឈាមរកមេរោគអេដស៍ ជូនកងទ័ពគ្រួសារទ័ព និងប្រជាជន នៅកងការពារព្រំដែនលេខ៥០៣ វរសេនាតូចលេខ៥១៤ និង៥០៥ ចំណុះយោធភូមិភាគទី៥។

- ប្រជុំក្រុមការងារអន្តរវិស័យដើម្បីនិរន្តភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដែលកិច្ចប្រជុំនេះពិភាក្សាអំពីៈ

  -ការណែនាំពីការបង្កើតក្រុមការងារអន្តរវិស័យ ដើម្បីនិរន្តភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍។

  -ការបង្កើតក្រុមការងារអន្តរវិស័យដើម្បីនិរន្តភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍

  -ពិភាក្សាការរៀបចំផែនការដើម្បីអនុវត្តសម្រាប់ក្រុមការងារអន្តរវិស័យដើម្បីនិរន្តភាព នៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

  -ពិភាក្សាអំពីការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការទទួលខុសត្រូវ របស់ក្រុមការងារអន្តរវិស័យ ដើម្បីនិរន្តភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

- ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការសម្របសម្រួលកម្ពុជា បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង-ស្ថាប័ន ដោយមានការចូលរួមពីគណៈប្រតិភូជាន់ខ្ពស់មូលនិធិសកលទីក្រុងហ្សឺណែវ ទទួលបន្ទុកគ្រប់គ្រងជំនួយសម្រាប់ប្រទេសកម្ពុជា តំណាងអង្គការសុខភាពពិភពលោក តំណាងទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិសហរដ្ឋអាមេរិក តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងក្រសួងសុខាភិបាល....។ កិច្ចប្រជុំនេះមានគោលបំណងបន្តកិច្ចសម្របសម្រួល ដើម្បីឈានទៅដាក់ឱ្យដំណើរការនូវរចនាសម្ព័ន្ធ និងយន្តការគ្រប់គ្រងគម្រោងជំនួយមូលនិធិសកលសម្រាប់ប្រយុទ្ធនឹងជំងឺអេដស៍ និងជំងឺរបេង ឆ្នាំ២០១៨-២០២០ ដែលត្រូវបាន

ព្រមព្រៀងដោយរាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិសកល ជាគោលការណ៍នាពេលកន្លងមក។ កិច្ចប្រជុំបានសម្រេចជូនភារកិច្ច ដល់ស្ថាប័ន និងផ្នែកពាក់ព័ន្ធ បន្តពិភាក្សា និងកំណត់ជាលម្អិតបញ្ចប់កិច្ចការដើម្បីពន្លឿនបែងចែកភារកិច្ច ការចូលរួមចំណែក ការចាត់ចែង និងការទទួលខុសត្រូវសម្រាប់អនុវត្តគម្រោងកម្មវិធីស្របតាមរចនាសម្ព័ន្ធ និងមុខងារដែលបានព្រមព្រៀងរួចហើយរវាងមូលនិធិសកល (ស្ថាប័នផ្តល់ជំនួយ) និងរាជរដ្ឋាភិបាលកម្ពុជា។

- នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ ឯកឧត្តមអគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានអញ្ជើញជាគណៈអធិបតីនៅក្នុងវេទិកាសម្របសម្រួល និងពង្រឹងកិច្ចសហការរវាងដៃគូពាក់ព័ន្ធ ក្នុងការអនុវត្តកម្មវិធីស្មាតហ្គីល។ ការរួមគ្នាគាំទ្រលើការរកឃើញករណីថ្មី និងអ្នកមិនបានដឹងពីស្ថានភាពរបស់ខ្លួន នៃស្ត្រីបម្រើសេវាកម្សាន្តសប្បាយ ត្រូវតែមានការចូលរួម ហើយមិនអាចខ្វះបានពីអាជ្ញាធរពាក់ព័ន្ធ ក្នុងនោះមន្ទីរទេសចរណ៍រាជធានី-ខេត្ត បានដើរតួនាទីសំខាន់ក្នុងការសម្របសម្រួលនៅតាមគ្រឹះស្ថានសេវាកម្សាន្ត ដែលជាគោលដៅចំនុច។

**<u>ផែនការសកម្មភាព និងទិសដៅបន្ទះ</u>**

- រៀបចំសេចក្តីព្រាង ដើម្បីស្នើសុំសិក្ខាសាលាដើម្បីបណ្តុះបណ្តាលបង្កើនសមត្ថភាពសមាជិកក្រុមប្រឹក្សាបច្ចេកទេសក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។
- បន្តរៀបចំកិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០១៧ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ នៅរមណីយដ្ឋានបឹងសំរិទ្ធ ខេត្តកំពង់ធំ។
- បន្តរៀបចំឯកសារ និងទំនាក់ទំនងជាមួយថ្នាក់ខេត្ត សម្រាប់ការចុះអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ និងសិក្ខាសាលាស្តីពីការបង្កបរិយាកាសអំណោយផល និងការអនុវត្តន៍កម្មវិធីដៃគូសហគមន៍សម្រាប់ក្រុមប្រជាជនប្រឈមមុខខ្ពស់។
- រៀបចំដំណើរការសម្រាប់វគ្គបណ្តុះបណ្តាល ស្តីពីកម្មវិធីដៃគូសហគមន៍សម្រាប់ក្រុមប្រជាជនប្រឈមមុខខ្ពស់ ចំនួន៦ខេត្តគឺៈ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ។
- បន្តតាមដានលើឯកសារ PIP 2018-2020 ដែលធ្វើដោយក្រសួងផែនការ។

ក្រោយពីបង្ហាញចប់ **ឯកឧត្តមប្រធានអង្គប្រជុំ** បានស្នើឱ្យបន្ថែមនូវសកម្មភាពដែលសមាជិកក្រុមការងារបានធ្វើកន្លងមក សម្រាប់ដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**<u>ប្រធានបទទី២</u>៖** ការពន្យល់ណែនាំលើលិខិតមួយចំនួន ដែលអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជម្រាបជូនទៅក្រសួង-ស្ថាប័ន ដោយឯកឧត្តម **ឈឹម ឃិនដារ៉េត** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងនោះមានលិខិតលេខ១៥២ អ.ជ.ប.ជ.អ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧ (សំណើរៀបចំឱ្យមានកញ្ចប់ថវិកាសម្រាប់សកម្មភាពការងារប្រយុទ្ធនឹងជំងឺអេដស៍ របស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង-ស្ថាប័ន)ឱ្យស្របតាមយុទ្ធសាស្ត្រជាតិទូលំទូលាយ និងស្របតាមអាណត្តិរបស់ក្រសួង ចាប់ពីឆ្នាំ២០១៨ តទៅ

បន្ទាប់មក **លោកវេជ្ជ. ទេព ណារិទ្ធ** ប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ បានជម្រាបជូនពីឈ្មោះក្រសួង-ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានផ្ញើនូវរបាយការណ៍សកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់ឆមាសទី១ ឆ្នាំ២០១៧ ក្នុងនោះមាន១៦ក្រសួង រាជធានី-ខេត្ត១៥ កាកបាទក្រហមកម្ពុជា និងអង្គការចំនួន៣ សម្រាប់ធ្វើជារបាយការណ៍បង្ហាញក្នុងកិច្ចប្រជុំក្រុមប្រឹក្សាគោលនយោបាយលើកទី១ ឆ្នាំ២០១៧ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ នៅខេត្តកំពង់ធំ។

ជាកិច្ចបន្ត ឯកឧត្តមប្រធានអង្គប្រជុំ ក៏បានជម្រាបជូនដល់សមាជិក-សមាជិកានៃអង្គប្រជុំថា **កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី៦ នឹងប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧** ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង១១ និង១៥នាទី ថ្ងៃ ខែ ឆ្នាំ ដដែល ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត៕

**ឧបសម្ព័ន្ធ៖**

- បញ្ជីវត្តមានអ្នកចូលរួម
- ឯកសារបទបង្ហាញផ្សេងៗ

ភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧

**ប្រធាននាយកដ្ឋាន**

**ទាក់ទង និងចលនាប្រភពធនធាន**

**វេជ្ជ. ឈា សិទ្ធិ**

បានឃើញ និងឯកភាព

**អគ្គលេខាធិការ**